ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ០២ សរណន

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩

# សារាចរណែនាំ
# ស្តីពីការជ្រើសរើស និងតែងតាំងមន្ត្រីរាជការស៊ីវិល

កន្លងមករាជរដ្ឋាភិបាលបានពិនិត្យឃើញថា មានក្រសួងស្ថាប័នមួយចំនួន បានធ្វើការជ្រើសរើស និងតែងតាំងមន្ត្រីរាជការក្រោមឱវាទពុំសមស្របទៅតាមគោលការណ៍នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងសារាចរលេខ ០១ សរ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ។ ចំពោះមុខដើម្បីពង្រឹងការអនុវត្តច្បាប់សហលក្ខន្តិៈមន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗជុំវិញការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីសំដៅបន្តរួមចំណែកក្នុងការអនុវត្តឱ្យបានជោគជ័យជាស្ថាពរនូវគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈ និងពង្រឹងនីតិរដ្ឋនោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម ៖

**១. __ការជ្រើសរើស__**

ក្នុងការជ្រើសរើសមន្ត្រីរាជការស៊ីវិលចូលក្នុងក្របខ័ណ្ឌរដ្ឋត្រូវអនុវត្តតាមបញ្ញត្តិដែលមានចែងក្នុងជំពូកទី II នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ជាពិសេសមាត្រា ១៣ បានចែងថា “ជាគោលការណ៍រាល់ការជ្រើសរើសបេក្ខជនឱ្យចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះដោយរាជរដ្ឋាភិបាល” ។ បែបបទនៃការជ្រើសរើសនេះមានចែងក្នុងសារាចរលេខ ០១ សរ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៧ ។

**២. __ការតែងតាំងមុខតំណែង__**

ជាគោលការណ៍ ការតែងតាំងឱ្យកាន់មុខតំណែងណាមួយនៃមុខងារសាធារណៈ របស់ក្រសួងស្ថាប័នត្រូវអនុវត្តចំពោះអ្នករាជការក្របខ័ណ្ឌ នៃក្រសួងស្ថាប័ននោះ ។

ការតែងតាំងនោះត្រូវផ្អែកលើសំណូមពរ ភារកិច្ចជាក់ស្តែង សញ្ញាប័ត្រជំនាញ បទពិសោធន៍ការងាររបស់សាមីជន ឱ្យសមស្របទៅតាមតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់ក្រសួងស្ថាប័ននីមួយ។ ការតែងតាំងឱ្យកាន់មុខតំណែងណាមួយក្នុងមុខងារសាធារណៈ ត្រូវអនុវត្តឱ្យបានសមស្របទៅតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលមានចែងជាពិសេស ក្នុងមាត្រា ២៨ ជំពូក III ស្តីពីសិទ្ធិក្នុងការតែងតាំង។

៣. **ការផ្ទេរ**

រាល់ការផ្ទេក្របខ័ណ្ឌមន្ត្រីរាជការ ពីក្រសួងស្ថាប័នមួយទៅក្រសួងស្ថាប័នមួយទៀត ជាគោលការណ៍ត្រូវមានការឯកភាពពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

៤. **ហាមឃាត់**

ក/ តាមស្មារតីខាងលើ មិនត្រូវបានអនុញ្ញាតឱ្យធ្វើការតែងតាំងមុខតំណែងមុខងារសាធារណៈក្នុងករណីដូចខាងក្រោម:

- អ្នកដែលគ្មានឈ្មោះក្នុងក្របខ័ណ្ឌមុខងារសាធារណៈ។
- អ្នកដែលកំពុងបំពេញកម្មសិក្សា ពុំទាន់តាំងស៊ប់ក្នុងក្របខ័ណ្ឌ។
- ការតែងតាំងថ្នាក់ស្មើ ក្នុងមុខតំណែងណាមួយ ដោយគ្មានក្នុងរចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងស្ថាប័ន។
- ការតែងតាំងបន្ថែមចំនួនមន្ត្រី ក្នុងមុខតំណែងអនុប្រធាននាយកដ្ឋាន អនុប្រធានការិយាល័យ អនុប្រធានមន្ទីរនៅខេត្ត ក្រុង ក្នុងករណីដែលនាយកដ្ឋាន ការិយាល័យ ឬមន្ទីរនោះមានអនុប្រធានចាប់ពី ២នាក់ឡើងទៅរួចហើយ។ ក្នុងករណីចាំបាច់ត្រូវពិគ្រោះជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យលើរចនាសម្ព័ន្ធជាមុន។

ខ/ ហាមផ្ទេរបញ្ចូលមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនូវមន្ត្រីបុគ្គលិកយោធា-នគរបាលជាតិ បុគ្គលិកស្ថិតក្នុងអង្គភាពម្ចាស់ការហិរញ្ញវត្ថុ ស្វ័យភិបាលសេដ្ឋកិច្ច និងក្របខ័ណ្ឌផ្សេងទៀត ដែលមិនស្ថិតនៅក្រោមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ក្នុងករណីពិសេសសត្រូវមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងទីស្តីការគណៈដ្ឋមន្ត្រី។

ទទួលបានសារាចរនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង និងរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះ ដោយស្មារតីទទួលខុសត្រូវ និងឱ្យមានប្រសិទ្ធភាពខ្ពស់។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**